ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.ធ២១៣-០១៩-៩៧១ ឆស.ការ

ថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលនៃកិច្ចប្រជុំគណ:កម្មាធិការគោលនយោបាយរូបិយវត្ថុ លើកទី៤៩

នៅថ្ងៃពុធ ១កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ២:៣០រសៀល ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចប្រជុំគណ:កម្មាធិការគោលនយោបាយរូបិយវត្ថុលើកទី៤៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ទេសាភិបាល និងជាប្រធានគណ:កម្មាធិការគោលនយោបាយរូបិយវត្ថុ។ អង្គប្រជុំបានពិភាក្សាទៅលើបច្ចុប្បន្នភាពនៃស្ថានភាពសេដ្ឋកិច្ចពិភពលោកនិងតំបន់ វឌ្ឍនភាព និងបញ្ហាប្រឈមនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជាព្រមទាំងគោលនយោបាយរូបិយវត្ថុសម្រាប់អនុវត្តនាគ្រាខាងមុខ។

ដើម្បីបន្តរក្សាស្ថិរភាពថ្លៃ សំដៅរួមចំណែកគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព គណ:-កម្មាធិការគោលនយោបាយរូបិយវត្ថុ បានសម្រេចបន្តអនុវត្តគោលនយោបាយរូបិយវត្ថុ ដូចខាងក្រោម៖

១/- បន្តរក្សាស្ថិរភាពអត្រាប្តូរប្រាក់ តាមរយ:ការធ្វើអន្តរាគមន៍ផ្អែកលើការប្រែប្រួលនៃទីផ្សារ
២/- បន្តផ្គត់ផ្គង់សន្ទនីយភាពជាប្រាក់រៀល សម្រាប់បំពេញតម្រូវការរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
៣/- អភិវឌ្ឍទីផ្សារនិងឧបករណ៍គោលនយោបាយ ដែលគាំទ្រដល់ការចរាចរប្រាក់រៀល និង
៤/- បន្តលើកកម្ពស់ការយល់ដឹងរបស់សាធារណជនពីសារ:សំខាន់និងតួនាទីប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចនិងសង្គម។

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**
**ប្រធានគណ:កម្មាធិការគោលនយោបាយរូបិយវត្ថុ**

ជា_ចាន់តូ

ចម្លងជូន ៖
- សមាជិកគណ:កម្មាធិការគោលនយោបាយរូបិយវត្ថុ
- ឯកសារ-កាលប្បវត្តិ